**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០៤៥...សហវ.ប្រក

**ប្រកាស**

**ស្តីពី**

**ការបង្កើតក្រុមការងារបច្ចេកទេសស្ថិតិ**
**និងសម្របសម្រួលព័ត៌មានទីផ្សារអចលនទ្រព្យ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ/បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៨៦ អនក្រ/បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញ អនុក្រឹត្យលេខ ១២៦ អនក្រ/បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញ អនុក្រឹត្យលេខ ១១៤ អនក្រ/បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ ស្តីពីការដាក់បញ្ចាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

- បានឃើញ អនុក្រឹត្យលេខ ៣៩ អនក្រ/បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី
- បានឃើញ ប្រកាសលេខ ១៣៣០ សហវ.ប្រក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើត ក្រុមការងារចងក្រងស្ថិតិ និងសម្របសម្រួលព័ត៌មានទីផ្សារអចលនវត្ថុ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំនួន ០២ ទៅ ០៣ រូប | សមាជិក |
| ៤. តំណាងសាលារាជធានីភ្នំពេញ ចំនួន ០២ រូប | សមាជិក |
| ៥. តំណាងធនាគារជាតិនៃកម្ពុជា ចំនួន ០១ រូប | សមាជិក |
| ៦. តំណាងអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ចំនួន ០២ រូប | សមាជិក |
| ៧. តំណាងអគ្គនាយកដ្ឋានពន្ធដារ ចំនួន ០១ រូប | សមាជិក |
| ៨. តំណាងអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ចំនួន ០១ រូប | សមាជិក |
| ៩. តំណាងសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ចំនួន ០១ រូប | សមាជិក |
| ១០. តំណាងសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា ចំនួន ០១ រូប | សមាជិក |
| ១១. តំណាងនាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន | លេខាធិការ។ |

សមាសភាពជាក់ស្តែង នៃក្រុមការងារចងក្រងស្ថិតិ និងសម្របសម្រួលព័ត៌មានទីផ្សារអចលនវត្ថុ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២.-**

ក្រុមការងារចងក្រងស្ថិតិ និងសម្របសម្រួលព័ត៌មានទីផ្សារអចលនវត្ថុ មានភារកិច្ចដូចខាងក្រោម៖

- ប្រមូល គ្រប់គ្រង និងចែករំលែកព័ត៌មានគ្នាទៅវិញទៅមកពាក់ព័ន្ធទៅនឹងវិស័យអចលនទ្រព្យ
- ពិនិត្យកម្រិតហានិភ័យនៃទីផ្សារអចលនវត្ថុសំដៅចាត់វិធានការទប់ស្កាត់វិបត្តិទាន់ពេលវេលា
- ស្នើសុំកិច្ចសហការពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីសម្រួលដល់ការប្រមូល និងចែករំលែកព័ត៌មាន
- រៀបចំរបាយការណ៍ប្រចាំត្រីមាស និងឆមាសអំពីព័ត៌មានទីផ្សារអចលនវត្ថុ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

សមាសភាពនៃក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានត្រូវកោះអញ្ជើញ និងដឹកនាំកិច្ចប្រជុំជំនួសតាមការប្រគល់សិទ្ធិពីប្រធាន។

**ប្រការ៤..**

ក្រុមការងារចងក្រងស្ថិតិ និងសម្របសម្រួលព័ត៌មានទីផ្សារអចលនវត្ថុ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

**ប្រការ៥..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦..**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី ...៣ ខែមករា ឆ្នាំ២០១៧

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ធនាគារជាតិនៃកម្ពុជា
- សាលារាជធានី ខេត្ត
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ